# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីរបាយការណ៍របស់ក្រសួងការបរទេសសហរដ្ឋអាមេរិកបានបញ្ចូលប្រទេសកម្ពុជាក្នុងបញ្ជីខ្មៅព្រោះរាជរដ្ឋាភិបាលខ្មែរមិនបានប្រយ័ុទ្ធឲ្យបានខ្លាំងក្លាប្រឆាំងនឹងការរត់ពន្ធមនុស្ស

web site: hoksavann.org
ថ្ងៃទី១១ មិថុនា ២០០៥

រដ្ឋាភិបាលនៃប្រទេសប្រជាធិបតេយ្យមានរដ្ឋាភិបាលសហរដ្ឋអាមេរិកជាមេដឹកមុខ បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាបំផុត អំពីការជួញដូរមនុស្សក្នុងពិភពលោក ។ ឧត្តមគតិនេះស្របតាមខ្លឹមសាររបស់ព្រះពុទ្ធសាសនា ដែលព្រះពុទ្ធបានប្រកាសជាង២៥០០ឆ្នាំមកហើយ ប្រឆាំងនឹងការជួញដូរមនុស្សនេះ ។ ក្នុងពេលថ្មីៗនេះ ក្រសួងការបរទេសសហរដ្ឋអាមេរិកបានចេញរបាយការណ៍មួយ បញ្ចូលប្រទេសកម្ពុជាក្នុងបញ្ជីខ្មៅព្រោះរាជរដ្ឋាភិបាលខ្មែរពុំបានធ្វើឲ្យជឿនលឿន ក្នុងការជួញដូរមនុស្សនៅប្រទេសកម្ពុជា ។ ការបញ្ចូលប្រទេសកម្ពុជាកម្រិតទី៣ជាកម្រិតដ៏ធ្ងន់ក្នុងបញ្ជីខ្មៅនេះ អាមេរិកអាចដាក់ទណ្ឌកម្មដល់ប្រទេសកម្ពុជា ។ ដូច្នេះរាជរដ្ឋាភិបាលខ្មែរគប្បីធ្វើឲ្យជឿនលឿនក្នុងការបំបាត់ការរត់ពន្ធមនុស្សនេះ កុំបន្ទោសគេអំពីការរិះគន់ក្នុងន័យស្ថាបនានេះ ព្រោះសហរដ្ឋអាមេរិកមានឥទ្ធិពលខ្លាំងណាស់ ទាំងផ្នែកនយោបាយនិងផ្នែកសេដ្ឋកិច្ចទៅលើប្រទេសក្នុងពិភពលោក បើអាមេរិកដាក់ទណ្ឌកម្មដល់ប្រទេសកម្ពុជា នឹងធ្វើឲ្យប្រទេសកម្ពុជាមានការលំបាកក្នុងការអភិវឌ្ឍន៍ជាទីបំផុតទៅថ្ងៃមុខ ។ ខ្មែរគ្រប់រូបគួរបំបាត់ជម្លោះផ្ទៃក្នុង ជាពិសេសជម្លោះនយោបាយ ដើម្បីប្រមូលកម្លាំងការពារជាតិនិងកសាងជាតិ ។ គួររំលឹកឡើងវិញខ្មែរធ្លាប់ឈ្លោះគ្នាឯង ហើយតែងតែពឹងបរទេស ម្ខាងពឹងសៀម ម្ខាងពឹងយួន ម្ខាងពឹងចិនកុម្មុយនិស្ត ម្ខាងពឹងសហរដ្ឋអាមេរិក មកកំទេចខ្មែរគ្នាឯង នេះជាមេរៀនប្រវត្តិសាស្ត្ររបស់អ្នកដឹកនាំខ្មែរ បានប្រើតាំងពីអតីតកាល រហូតដល់បច្ចុប្បន្នកាលនេះ ហើយអ្នកទទួលរងគ្រោះ គឺប្រជាពលរដ្ឋខ្មែរ ព្រោះសមរភូមិនៅលើទឹកដីខ្មែរ ដែលម្ខាងៗខំប្រឹងប្រែងប្រមូលគ្រាប់បែកគ្រាប់កាំភ្លើង ដែលបរទេសផ្តល់ឲ្យ យកមកសម្លាប់ខ្មែរយកមកអារកខ្មែរ ដែលជះឥទ្ធិពលអាក្រក់ដល់មាតុប្រទេសរបស់ខ្លួនរហូតមកដល់សព្វថ្ងៃនេះ ។ អ្នកកាន់អំណាចថៃគេឈ្លោះគ្នាដែរ ប៉ុន្តែម្ខាងៗគេពុំដែលពឹងបរទេស ឲ្យមកជួយកំទេចថៃគ្នាគេដូចខ្មែរឡើយ មហាអំណាចណាក៏គេយកជាមិត្តទាំងអស់ គឺអាមេរិកក៏គេយកជាមិត្ត ចិនកុម្មុយនិស្តក៏គេយកជាមិត្ត ។ ត្រង់នេះហើយដែលធ្វើឲ្យប្រទេសគេមានស្ថេរភាពខាងផ្លូវនយោបាយ និងចំរើនលូតលាស់ខាងសេដ្ឋកិច្ច ។ ចំពោះការជួញដូរមនុស្សនៅប្រទេសកម្ពុជានេះ ក្នុងរបាយការណ៍ក្រសួងការបរទេសសហរដ្ឋអាមេរិកបានចែងថា មានអ្នកកាន់អំណាចខ្មែរគឺមន្ត្រីរាជការខ្មែរខ្លះ បានពាក់ព័ន្ធនឹងការជួញដូរនេះ ។ ដូច្នេះបើការពោលអះអាងនេះជាការពិតមែន ធ្វើដូចម្តេចនឹងកំចាត់បាន និងធ្វើដូចម្តេចនឹងគេខំប្រឹងចាត់ចែងកំចាត់ ព្រោះខ្លួនគេ (អ្នកកាន់អំណាច) ជាអ្នកប្រព្រឹត្ត បានសេចក្តីថា អ្នកទៅបង្ក្រាបចោរទៅចូលដៃជាមួយចោរ ធ្វើដូចម្តេចចាប់ចោរបាន ? ចំពោះរបាយការណ៍នេះ ទំនងជាពោលចំពោះភ្នាក់ងាររាជការខ្លះប្រព្រឹត្តអំពើបែបនេះ ពុំមែនជាភ្នាក់ងាររាជការទូទៅឡើយ ។ ការជួញដូរមនុស្សឬចាប់មនុស្សលាក់នេះ ព្រះពុទ្ធសាសនាបានហាមជាដាច់ខាត មិនឲ្យពុទ្ធបរិស័ទព្រះអង្គប្រព្រឹត្តឡើយ ព្រោះជាមនុស្សជាតិដូចគ្នា ។ តាមរបាយការណ៍របស់ក្រសួងការបរទេសសហរដ្ឋអាមេរិកថា កុមារីខ្មែរជាច្រើនបានត្រូវគេបញ្ឆោតឲ្យធ្វើជាស្រីពេស្យានៅប្រទេសថៃ នៅម៉ាឡេស៊ី នៅហុងកុង ។ ចំណែកមនុស្សប្រុសខ្មែរជាច្រើន បានត្រូវគេបង្ខំឲ្យធ្វើការក្នុងរបរនេសាទ ក្នុងរបរកសិកម្មនៅប្រទេសវៀតណាម នៅថៃ និងនៅម៉ាឡេស៊ី ។ ឯក្មេងៗខ្មែរបានត្រូវគេបង្ខំ ឲ្យដើរសុំទាននៅប្រទេសថៃ និងប្រទេសវៀតណាម ។ ប្រទេសកម្ពុជាជាប្រទេសឆ្លងកាត់ស្ត្រីពីប្រទេសវៀតណាម យកទៅលក់ធ្វើស្រីពេស្យានៅប្រទេសថៃនិងម៉ាឡេស៊ី ។ មុខរបរនេះបានលូតលាស់ខ្លាំង ដោយមន្ត្រីរាជការខ្មែរពុករលួយ និងប្រព័ន្ធតុលាការខ្មែរទន់ខ្សោយ ពុំបានដាក់ទោសទណ្ឌកម្មដល់អ្នកប្រព្រឹត្តអំពើឧក្រិដ្ឋអមនុស្សធម៌នេះ ឲ្យបានខ្លាំងតាមទោសកំហុស ។ កាលពីឆ្នាំ ២០០៤ អង្គការក្រៅរដ្ឋាភិបាលមួយ ដែលអាមេរិកផ្តល់ថវិកានៅភ្នំពេញជាអង្គការជួយស្ត្រីមានវិបត្តិ បានរំដោះស្ត្រីនៅសណ្ឋាគារឆៃហ្វ២ជិតមួយរយនាក់ ដោយចោទថា ស្ត្រីទាំងនោះត្រូវគេកេងប្រវ័ញ្ចខាងផ្លូវភេទ ប៉ុន្តែក្រោយមក បានត្រូវអ្នកមានអំណាចមួយក្រុម ដោយមានកងកម្លាំងប្រដាប់អាវុធផង បានរំដោះយកទៅវិញ ។ ព្រឹត្តិការណ៍នេះ សហរដ្ឋអាមេរិកបានចោទរដ្ឋាភិបាលខ្មែរថា ពុំបានដោះស្រាយ ដោយឆ្លើយតបតាមការពិតឡើយ ដោយមានការសង្ស័យថា មន្ត្រីរាជការខ្មែរខ្លះទុកស្ត្រីទាំងនោះសំរាប់ការសប្បាយរបស់ខ្លួនម្តងម្កាល ក្នុងការរួមភេទ បានជាខំការពារស្ត្រីទាំងនោះទុកក្នុងសណ្ឋាគារនោះដដែល ។

ប្រទេសកម្ពុជាសព្វថ្ងៃនេះ ដល់ថ្នាក់អ្នកមានអំណាចតែងតែមានប្រៀប មានជ័យជំនះ ទៅលើប្រជាពលរដ្ឋអ្នកទាន់ខ្សោយ អ្នកស្លូតត្រង់ជានិច្ច ដូចជាការរំលោភយកដីប្រជាជន ការបញ្ឆោតយកកូនស្រីអ្នកស្រុកមករួមភេទ ដោយការឲ្យប្រាក់បន្តិចបន្តួចជារបៀបទិញដូរ បង្ខូចអនាគតប្រជាជនខ្លួន ។ អំពើប្រព្រឹត្តអនាចារអមនុស្សធម៌នេះ មិនត្រឹមតែមន្ត្រីរដ្ឋការខ្លះដែលកាន់ការខាងនីតិប្រតិបត្តិទេ សូម្បីអ្នកកាន់ការខាងនីតិបញ្ញត្តិខ្លះ ក៏បានប្រព្រឹត្តដូចគ្នាដែរ ។ ពិសេសមានអ្នកឧកញ៉ាខ្លះមានវ័យចាស់ ពុំព្រមចូលចិត្តសុំសីលទេ បានយកឋានៈខ្លួនជាឧកញ៉ា ទៅប្រលោមយកស្រីខ្មែរ ដែលមានវ័យក្មេងជាច្រើននាក់ ឲ្យបំរើខ្លួនក្នុងផ្លូវកាមគុណ ។ ជនកំហូចនេះ គេពុំគិតអំពីតម្លៃទំនៀមទំលាប់ដ៏ល្អរបស់ខ្មែរដែលមានពីបូរាណមកទេ ។ ដូច្នេះបញ្ជាក់ថា ពុំមែនត្រឹមតែជនបរទេសទេដែលរំលោភស្ត្រីខ្មែរ គឺខ្មែរខ្លួនឯងរំលោភលើគ្នា ជាពិសេសអាជ្ញាធរមានអំណាចនេះតែម្តង ។

មានកុមារីនិងនារីខ្មែរបានទៅបំរើគេតាមផ្ទះ នៅតាមទីក្រុង មានក្រុងភ្នំពេញជាដើម បានត្រូវម្ចាស់ផ្ទះខ្លះធ្វើបាបរហូតរំលោភផ្លូវភេទទៀតផង ។ ក៏ដូចគ្នានឹងក្រុមហ៊ុនមួយបានបញ្ជូននារីខ្មែរ ឲ្យទៅបំរើគេក្នុងគ្រួសារនៅប្រទេសម៉ាឡេស៊ី ក៏បានត្រូវគ្រួសារខ្លះធ្វើបាប រហូតរំលោភផ្លូវភេទដូចគ្នា ។

ចំពោះស្ត្រីបំរើស្រាបៀរត្រូវអតិថិជនមើលងាយ ធ្វើបាបរហូតរំលោភផ្លូវភេទផង ។ ការមើលងាយ ការរំលោភនោះ គ្មានអន្តរាគមន៍ពីក្រុមហ៊ុននិងពីអាជ្ញាធរខ្មែរឡើយ ។ នេះបញ្ជាក់ថា ជាស្រុកអត់ច្បាប់ អ្នកណារំលោភលើអ្នកណា គ្មានច្បាប់ធានាជួយការពារឡើយ ។ នៅប្រទេសជឿ

នលឿនខាងច្បាប់និងខាងការគោរពសិទ្ធិមនុស្ស មិនថាតែការរំលោភផ្លូវភេទទេ សូម្បីពាក្យសំដីមើលងាយ ប៉ូលីសមកដល់ភ្លាមហើយហាមប្រាម បើមិនស្តាប់ទេ ប៉ូលិសដាក់ខ្នោះភ្លាម រួចបញ្ជូនទៅការិយាល័យប៉ូលិសធ្វើតាមច្បាប់ ។ បើមានការរំលោភផ្លូវភេទដោយជាក់ស្តែង ជាអំពើឧក្រិដ្ឋកម្មជាក់ស្តែង ។ មួយទៀត បើមានស្ត្រីអ្នករងគ្រោះប្តឹងថាមានរំលោភផ្លូវភេទ ប៉ូលិសខាប់ឃាត់ខ្លួនសិនដែរ ដើម្បីសាកសួរនិងធ្វើកំណត់ហេតុទៅតុលាការ ។ ចុះស្ត្រីខ្មែរដ៏អភ័ព្វដែលធ្វើការក្នុងក្រុមហ៊ុនស្រាបៀរ ហេតុដូចម្តេចបានជាអាជ្ញាធរខ្មែរពុំអនុវត្តតាមច្បាប់ បណ្តោយឲ្យអតិថិជនជាជនពាលខ្លះរំលោភលើស្ត្រីទាំងនោះ ។ ដំបូងត្រូវធ្វើច្បាប់ឲ្យក្រុមហ៊ុននោះអនុវត្ត បើក្រុមហ៊ុននោះពុំមើលការខុសត្រូវ បណ្តោយឲ្យភ្ញៀវមើលងាយ ឬដល់ថ្នាក់រំលោភលើស្ត្រីទាំងនោះ ក្រុមហ៊ុននោះត្រូវទទួលខុសត្រូវ ដោយបិទក្រុមហ៊ុននោះតែម្តង ។ ពិសេស នើយោលតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ល្បែង ស្រាឬការលក់ស្រា និងផឹកស្រានេះ ជាជំនួញឬជាអំពើអបាយមុខ ដែលជាប្រធាននៃសេចក្តីវិនាស ត្រូវបិទផ្ទះលក់ស្រា ឬរោងបាបទាំងអស់នោះតែម្តង ដើម្បីកុំឲ្យមានបញ្ហាបែបនេះ ។

ដូចបានពោលមកហើយ របាយការណ៍របស់ក្រសួងការបរទេសអាមេរិក ដែលបានពោលអំពីការជួញដូរមនុស្សនេះ ពុំមែនថ្កោលទោសតែរដ្ឋាភិបាលខ្មែរទេ គឺបានថ្កោលទោសប្រទេសជាច្រើន មានប្រទេសភូមា ប្រទេសកូរ៉េខាងជើង ប្រទេសគុយបាជាដើម តែប្រទេសទាំងនោះពុំមានប្រតិកម្មអ្វីឡើយ មានតែរដ្ឋាភិបាលខ្មែរទេដែលមានប្រតិកម្ម ដោយមិនចង់ឲ្យគេរិះគន់ ចង់បិទបាំងការពិតនេះ ។ គួរតែរដ្ឋាភិបាលខ្មែរខំប្រឹងប្រែងទប់ស្កាត់អំពើជួញដូរមនុស្ស ឲ្យបានខ្លាំងក្លាឡើងថែមទៀត កុំឲ្យមានអ្នករងគ្រោះខ្មែរ ដែលកើតអំពីការជួញដូរនេះមានតទៅទៀត និងដើម្បីស្តារកេរ្តិ៍ឈ្មោះប្រទេសកម្ពុជាឲ្យល្អឡើងវិញ ប្រសើរជាងការកែខ្លួនពីការរិះគន់របស់សហរដ្ឋអាមេរិក ។ ដើម្បីកំចាត់ការជួញដូរមនុស្សដែលជាមុខរបរខុសច្បាប់ ទាំងផ្លូវលោកទាំងផ្លូវធម៌ អាទិភាពទីមួយ គឺត្រូវចាប់មន្ត្រីរាជការ ដែលមានការពាក់ព័ន្ធក្នុងការជួញដូរមនុស្សនេះ យកទៅកាត់ទោសតាមច្បាប់ ។ ប្រព័ន្ធតុលាការត្រូវអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ មិនត្រូវពុករលួយដោយការស៊ីសំណូក ឬដោយការខ្លាចអំណាចនៃអ្នកមានអំណាច បើមានកំហុសត្រូវតែប្រឈមមុខចំពោះមុខច្បាប់ដូចគ្នា ។ បើតុលាការពុំអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ ក្រុមប្រឹក្សាអង្គចៅក្រមត្រូវធ្វើទោសសមាជិកតុលាការនោះតាមច្បាប់ ។ ក្រៅពីនោះ រាជរដ្ឋាភិបាលត្រូវធ្វើអនុសាសន៍អប់រំប្រជាពលរដ្ឋ ឲ្យស្គាល់ល្បិចបោកបញ្ឆោតរបស់ជនឧក្រិដ្ឋជួញដូរមនុស្សនេះ ។៚